**សកម្មភាព៖ ល្បែងអានសៀវភៅ**

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

**គោលបំណង** ៖

**(ភាសាខ្មែរ)** ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ។

ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សន្លឹកកិច្ចការ និងខ្មៅដៃពណ៌

**ការរៀបចំ** ៖ គ្រូអានសៀវភៅឱ្យបានច្រើន ដើម្បីឱ្យស្គាល់សាច់រឿងកាន់តែច្បាស់។

សរសេរសំណួរមួយចំនួនដែលអ្នកចង់សួរក្មេងៗ ហើយសំណួរមានដូចជា៖

- តើអ្វីដែលមានពណ៌បៃតងនៅក្នុងរឿងនេះ?
- តើស្បងរបស់ព្រះសង្ឃមានពណ៌អ្វី?
- តើខេទីមកពីប្រទេសណា?
- តើអ្នកទាំងអស់គ្នាមានចងចាំទេ ថាតើមួកការពារសុវត្ថិភាពរបស់យ៉េកមានពណ៌អ្វី?

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងអានរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?" ឱ្យកូនៗស្តាប់ទាំងអស់គ្នា។
2. បង្ហាញក្មេងពីសៀវភៅរឿងនេះ។
3. ចូរឱ្យក្មេងនិយាយតាមពាក្យថា ‹‹សៀវភៅ››
4. ប្រាប់ក្មេងៗពីរបៀបប្រើប្រាស់ និងរបៀបបើកសៀវភៅ ។
5. ឱ្យក្មេងៗក្រឡេកមើលទៅក្របសៀវភៅ ឱ្យពួកគេចងចាំរូបភាព និងចំណងជើងរបស់សៀវភៅ ។
6. ពន្យល់ពួកគេពីចំណងជើងរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"
7. ចូរឱ្យក្មេងនិយាយតាមពាក្យថា ‹‹ចំណងជើង››
8. អានសៀវភៅដោយបង្ហាញរូបភាពយឺតៗ និងច្បាស់ៗ ។
9. បង្ហាញរូបភាពម្តងទៀត នឹងនិយាយអំពីរូបភាពទាំងនោះ ។

10. ចូរសួរសំណួរដែលបានរៀបចំទាំងនោះទៅកាន់ក្មេងៗ ។
11. ឆ្លើយសំណួរណាមួយដែលក្មេងៗមិនច្បាស់ ។